00800252

E172/17

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 04 / 2012
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២

**ផ្ញើជូន៖** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ

ដើម្បីជួយសម្រួលដល់ការរៀបចំផែនការរបស់អង្គជំនុំជម្រះ ភាគី និង អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) អង្គជំនុំជម្រះសូមជូនព័ត៌មានបន្ថែមទៀតពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំដូចខាងក្រោម ដែលមាននៅក្នុងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សវនាការដំណាក់កាលដំបូងក្នុងនៃសំណុំរឿង ០០២ (ឯកសារលេខ E131/1.1)៖

- លោក David Chandler៖ នឹងត្រូវស្តាប់សក្ខីកម្មបន្ទាប់ពីការឈប់សម្រាករដូវក្តៅអឺរ៉ុបរួច។កាលបរិច្ឆេទនឹងប្រកាសជូននៅពេលក្រោយ(រយៈពេលសួរសំណួរដោយអង្គជំនុំជម្រះ និងភាគីទាំងអស់ប្រហែល ៥ ថ្ងៃ)។

- លោក Philip Short៖ នឹងត្រូវស្តាប់សក្ខីកម្មក្នុងរយៈប៉ុន្មានខែខាងមុខទៀតនេះ បន្ទាប់ពីការឈប់សម្រាករដូវក្តៅអឺរ៉ុបរួច។ កាលបរិច្ឆេទនឹងប្រកាសជូននៅពេលក្រោយ (រយៈពេលប្រហែល ៦ ថ្ងៃ)។

- លោក Henri Locard៖ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីថា អ្នកជំនាញដែលភាគីបានស្នើសុំរូបនេះនឹងមិនត្រូវស្តាប់សក្ខីកម្មមុនខែ តុលា ឆ្នាំ ២០១២ នោះទេ។ ព័ត៌មានបន្ថែមដែលពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទស្តាប់អ្នកជំនាញរូបនេះ នឹងធ្វើឡើងក្នុងពេលវេលាដ៏សមស្របខាងមុខ។

- លោកស្រី Elizabeth Becker៖ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញរូបនេះពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២ (រយៈពេលប្រហែល ៥ ថ្ងៃ)។ អង្គជំនុំជម្រះនឹងបញ្ជាក់អំពីការស្តាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះក្នុងពេលវេលាដ៏សមស្របខាងមុខ។

- លោក Ben Kiernan៖ កាលបរិច្ឆេទដែលនឹងត្រូវកែប្រែសម្រាប់ស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំរូបនេះ នឹងត្រូវធ្វើឡើងក្នុងពេលវេលាដ៏សមស្របខាងមុខ។ អង្គជំនុំជម្រះមិនរំពឹងថានឹងអាចស្តាប់សក្ខីកម្មអ្នកជំនាញរូបនេះក្នុងពេលឆាប់ៗនេះទេ។

- លោក អ៊ា ម៉េងទ្រី និង លោកស្រី Anne Guillou៖ អង្គជំនុំជម្រះមិនទាន់បានកំណត់កាលបរិច្ឆេទសម្រាប់ស្តាប់សក្ខីកម្មអ្នកជំនាញទាំងពីររូបនេះនៅឡើយទេ។ ព័ត៌មានបន្ថែមនឹងផ្តល់ជូនក្នុងពេលវេលាដ៏សមស្របខាងមុខ។